

# ជំពូកទី ២
# កិច្ចចាប់ផ្តើម



ទារកចាប់ផ្តើមរៀនយ៉ាងឆាប់រហ័សក្រោយពេលនាងកើតមកភ្លាម។ នៅអំឡុង 5 ឆ្នាំដំបូង នាងនឹងរៀនបំណិនយ៉ាងច្រើន និងចេះបំណិនទាំងនោះយ៉ាងឆាប់រហ័ស ហើយងាយស្រួលជាងពេលណាៗទាំងអស់នៅក្នុងជីវិតនាង។ ដូច្នេះជាការសំខាន់ត្រូវចាប់ផ្តើមសកម្មភាពជំនួយទាន់អាយុនៅតិច ឱ្យបានកាន់តែឆាប់តាមដែលអាចធ្វើបាន។

អ្នកអាចរកឃើញថាវាពិតជាពិបាក ដើម្បីដឹងពីរបៀបចាប់ផ្តើមធ្វើសកម្មភាពទាំងនេះជាមួយកូនអ្នក។ នៅក្នុងជំពូកនេះមានរចនាគំរូដើម្បីជួយអ្នកឱ្យចេះចាប់ផ្តើម និងមានផ្ទុកព័ត៌មានស្តីពី :-

- ការប្រើព័ត៌មាននៅក្នុងសៀវភៅឱ្យមានប្រយោជន៍បំផុត។
- ការសំរេចថាតើសកម្មភាពណាមួយ ត្រូវចាប់ផ្តើមអនុវត្តមុនដំបូង។
- ការយកសកម្មភាពទាំងនេះទៅបញ្ច្រាបចូលក្នុងជីវិតរស់នៅនៃក្រុមគ្រួសាររបស់អ្នក។

## តើសៀវភៅនេះអាចជួយបានដោយរបៀបណា?

នៅក្នុងសៀវភៅនេះយើងផ្តល់ព័ត៌មាន, គំនិត, ហេតុផល, និងផ្តល់យោបល់សំរាប់ធ្វើអ្វីៗដើម្បីជួយដល់កូនអ្នក។ អ្នកអាចប្រើសៀវភៅនេះដើម្បី :-

- ការស្វែងយល់ឱ្យកាន់តែច្រើនអំពីភាពពិការភ្នែក និងការអភិវឌ្ឍរបស់កុមារ។
- រៀនអំពីហេតុផលសំរាប់អនុវត្តសកម្មភាពនីមួយៗ។ ប្រការនេះនឹងធ្វើឱ្យអ្នកកាន់តែងាយស្រួលដើម្បីបង្កើតសកម្មភាពដែលធ្វើឱ្យបានសំរេចគោលបំណងដូចគ្នា។
- រៀនពីឪពុកម្តាយឯទៀតដែលធ្លាប់ចិញ្ចឹមកូនមានបញ្ហាគំហើញ។
- អភិវឌ្ឍ និងអនុវត្តសកម្មភាពសិក្សាដែលមានដំណើរការល្អសំរាប់អ្នក និងកូន។

## តើសកម្មភាពមួយណាដែលខ្ញុំគួរអនុវត្តមុនដំបូង?

ជារឿយៗឪពុកម្ដាយតែងគិតថា ពួកគាត់ត្រូវការការបណ្ដុះបណ្ដាលពិសេសដើម្បីធ្វើផែនការសកម្មភាពជំនួយទាន់អាយុនៅតិចសំរាប់កូនគាត់ ។ ប៉ុន្ដែប្រការនេះមិនពិតឡើយ ។ ក្នុងនាមអ្នកជាឪពុកម្ដាយ អ្នកស្គាល់កូនរបស់ខ្លួនឯងច្បាស់ជាងនរណាៗទាំងអស់ ។ ចូរចាប់ផ្ដើមដោយសួរខ្លួនឯងនូវសំណួរទាំងនេះ ដើម្បីសំរេចចិត្ដអំពីសកម្មភាពអ្វីខ្លះដែលអ្នកត្រូវអនុវត្ដមុនដំបូង ។

### តើមានចំណុចណាខ្លះដែលកុមារដទៃមានអាយុស្រករកូនខ្ញុំកំពុងធ្វើ តែកូនខ្ញុំមិនអាចធ្វើបាន?




បើសិនជាដូច្នេះមែន កូនអ្នកត្រូវការជួយជាពិសេសដើម្បីរៀនបំណិនទាំងនេះ ។ ចូរជ្រើសរើសសកម្មភាពដែលកសាងបំណិនទាំងនេះ នោះនឹងអាចជួយកូនអ្នកឱ្យតាមទាន់ជាមួយកុមារដទៃទៀត ។

### តើផ្នែកណាខ្លះនៃការអភិវឌ្ឍសំរាប់កូនខ្ញុំ ដែលខ្ញុំព្រួយបារម្ភជាពិសេស?

ទាំងនេះប្រហែលជាផ្នែកដែលកូនអ្នកលូតលាស់យឺតជាងកុមារដទៃ ឬក៏ប្រហែលជាផ្នែកនៃការអភិវឌ្ឍដែលសំខាន់ជាពិសេសចំពោះអ្នក និងក្រុមគ្រួសារ ។




សំរាប់ព័ត៌មានបន្ថែមស្ដីពីអាយុ និងលំដាប់លំដោយដែលកុមាររៀនបំណិនថ្មីៗតាមធម្មតា ចូរអានតារាងអភិវឌ្ឍកុមារដែលចាប់ផ្ដើមនៅទំព័រ 176 ។

## ការស្វែងរកសកម្មភាពដែលអាចជួយបាន

នៅពេលអ្នកស្វែងរកឃើញផ្នែកដែលកូនត្រូវការការជួយជ្រោមជ្រែង ចូរអានត្រង់តារាងមាតិកាដើម្បីរកជំពូកដែលគ្របដណ្ដប់អំពីផ្នែកនៃការអភិវឌ្ឍនេះ ។ ជំពូកនីមួយៗមានផ្ទុកព័ត៌មាន និងសកម្មភាពដើម្បីជួយកូនរបស់អ្នករៀនបំណិនថ្មីៗ ។ ឧទាហរណ៍ :-




សកម្មភាពដំបូងក្នុងជំពូកនីមួយៗជួយឱ្យកុមាររៀនបំណិនសាមញ្ញបំផុតនៃការអភិវឌ្ឍក្នុងផ្នែកនោះ ។ ខណៈដែលកុមារចេះបំណិនទាំងនេះហើយ នាងអាចចាប់ផ្ដើមធ្វើការលើបំណិនទាំងឡាយដែលពិបាកជាងមុន ដែលបានអធិប្បាយក្នុងជំពូកខាងមុខៗទៀត ។ បើកូនអ្នកចេះបំណិនដែលបានអធិប្បាយខ្លះៗហើយ សូមចាប់ផ្ដើមអនុវត្តបំណិននោះជាបន្ទាន់ បន្តពីបំណិនដែលនាងចេះហើយ ។ បើនាងមិនទាន់ចេះបំណិនណាមួយនោះ ចូរចាប់ផ្ដើមអនុវត្តពីខាងដើមនៃជំពូក ។

ចូរអនុវត្តបំណិនតាមលំដាប់លំដោយដែលបានចែងនៅក្នុងជំពូក ។ ប្រការនេះគឺជាការសំខាន់ពីព្រោះកុមារអភិវឌ្ឍបំណិនមួយជំហានម្ដងៗទៅតាមលំដាប់លំដោយពិតប្រាកដ ។ **ការព្យាយាមបង្រៀនកូនអំពីបំណិនជ្រៅៗ មុនពេលនាងរៀនបំណិនតូចៗ និងងាយៗដែលត្រូវចេះមុន អាចឈានទៅរកការខកចិត្តទាំងអ្នក និងកូន ។**

## បញ្ច្រាបសកម្មភាពនៅក្នុងការរស់នៅប្រចាំថ្ងៃរបស់អ្នក

វាគឺជាការសំខាន់ដើម្បីគិតពិចារណាពីរបៀបអនុវត្តសកម្មភាពជំនួយទាន់អាយុនៅតិច តាមរបៀបដែលមិនបង្កើនការងារច្រើនសំរាប់អ្នក ។ ការបង្រៀនកូននឹងកាន់តែងាយស្រួលសំរាប់អ្នក និងមិនបង្កើនពេលបន្ថែមដោយការធ្វើឱ្យសកម្មភាពប្រចាំថ្ងៃក្លាយទៅជាបទពិសោធន៍សំរាប់ការសិក្សារៀនសូត្រ ។



**ចូរពន្យល់ប្រាប់កូនអំពីសម្លេង និងក្លិននានា នៅពេលអ្នកទៅផ្សារ។**



**ចូរនិយាយអំពីអ្វីដែលអ្នកកំពុងធ្វើ។**

## មនុស្សជាច្រើនអាចជួយធ្វើសកម្មភាពទាំងនេះ

ចូរលើកទឹកចិត្តសមាជិកក្រុមគ្រួសារ អ្នកជិតខាង និងមិត្តភក្តិឱ្យចូលរួមជាអ្នកជួយផងដែរ ។ ជារឿយៗមនុស្សនៅជុំវិញអ្នកតែងតែចង់ជួយ តែមនុស្សទាំងនោះអាចទើសទាល់ក្នុងចិត្ត ពីព្រោះពួកគេមិនដឹងថាត្រូវជួយរបៀបណា ។ ចូរចែករំលែកនូវអ្វីដែលអ្នកបានដឹងអំពីបញ្ហាគំហើញ, សកម្មភាពដែលអ្នកនិងកូនកំពុងអនុវត្ត, ព្រមទាំងហេតុផលសំរាប់ធ្វើសកម្មភាពទាំងនេះដល់ពួកគេ ។




ក្មេងៗក៏អាចជួយអ្នកបានដែរ បើសិនជាអ្នកបង្ហាញរបៀបដែលត្រូវធ្វើដល់ពួកគេ ។ ចូរពន្យល់ពួកគេពីការកែសម្រួលល្បែងលេងមួយចំនួន ដែលអាចដាក់បញ្ចូលឱ្យកូនអ្នកលេងជាមួយពួកគេបាន ។ បន្ទាប់មកលើកទឹកចិត្តពួកគេឱ្យច្នៃបង្កើតគំនិតថ្មីៗដោយខ្លួនឯង ។

